R 12-9-53
"Louk krou Ek ei nœung kaun seus bèi néak"

RÉGIE DU DÉPÔT LÉGAL

# រឿង
# លោកគ្រូឯកអី
# នឹងកូនសិស្សបីនាក់



ឋ-ឋ
168

ARCHIVES NATIONALES
RÉGIE DU DÉPOT LÉGAL

ARCHIVES NATIONALES
COTE B. 63. 649 86

# រឿង

# លោកគ្រូអ៊ឹកអ៊ី

អ្នកនិពន្ធ

កវីសុខ - បឿ

រក្សាសិទ្ធិ

ការផ្សាយរបស់

ផ្ទះលេខ ៣, វិថីវ៉ាន់វូឡង់ហូវែន ភ្នំពេញ

ព. ស. ២៤៩៦

គ. ស. ១៩៥៣

# រឿងលោកគ្រូអ៊ិកអ៊ី

## និងកូនសិស្សពាក់ផេះ

សុខ - បឿ ខ្ញុំបានរៀបរៀងដោយមានរឿងពីព្រេងនាយ ដែលបុរាណសម័យលោកបាននិយាយដំណាលតៗគ្នាមក កាលខ្ញុំដែលរៀបរៀងរឿងនេះ តាមលំដាប់ហូរហែតាំងពីខាងដើមដល់ខាងចុងតែម្ដង ៗ លោកគ្រូនេះកាលពីដើមមិនមែនឈ្មោះ អ៊ិកអ៊ីដូច្នេះទេ គឺឈ្មោះលោកតាសួស ដល់ទៅខាងចុងទើបបានពិតថា លោកគ្រូអ៊ិកអ៊ីដូច្នេះ សូមលោកអ្នកអានអ្នកស្ដាប់ទាំងឡាយ ចូលចិត្តពីហេតុខាងដើមដរាបដល់ខាងចុងដូចតទៅ ៗ

ក្រី សុខ បឿ

- រៀបរៀង -

មានសេចក្ដីដំណាលថា ក្នុងសម័យកាលដែលកន្លងទៅហើយនោះ មានលោកនេនមួយអង្គ អ្នកស្រុកគេតែងហៅថាលោកតាសួស ៗ នោះ ជានេនខ្ជីខ្ជា យប់ៗដើរស្វែងក្នុងភូមិអ្នកស្រុក ដើម្បីលួចមាន់-អង្ករ-ត្រីសាច់ មាសប្រាក់កាក់ប្រាស យកទៅទិញសុរាយកមកផឹកស៊ីបាយ យប់តែរឿយ ៗ មានមនុស្ស ៣ នាក់ រួមចូលផឹកស៊ីជាមួយផង លុះនៅយូរ ៗ ទៅ តាសួសរកប្រាក់នឹងទិញស្រាពុំបាន មួយទៀតគិតថា បើនៅយូរខ្លាចក្រែងអ្នកស្រុកគេដឹង ថាអញជាមនុស្សពុតអាក្រក់ គេនឹងបណ្ដេញអញចេញពីវត្តអារាម ទើបនិយាយពីគ្រោះគ្នានឹងមនុស្ស ៣ នាក់នោះថាយើងនៅក្នុងស្រុកធំនោះ ក្រប្រាក់ចាយណាស់ ឧបាសក ឧបាសិកាញោមវត្តនេះ គេពុំមានសទ្ធា ធ្វើបុណ្យធ្វើទាននឹងយើងទេ បើដូច្នោះគួរពួកយើងបបួលគ្នាចេញទៅស្រុកក្រៅ ដើរកៃខកុហកបញ្ឆោតអ្នកស្រុកស្រែចម្ការ ដោយឧបាយកលផ្សេងៗ គឺអញធ្វើជាលោកធុតង្គរុក្ខមូល ហៅឯង ៣ នាក់ធ្វើជាកូនសិស្សឧបដ្ឋាកដើរតាមក្រោយ ដើរនិយាយបញ្ចុះបញ្ចូលបបួលអ្នកព្រៃ ឲ្យគេជឿថាអញវិសេសខាងធុតង្គរុក្ខមូលគេនឹងនិមន្តធ្វើបុណ្យទាន បានបច្ច័យហើយយើងកៃខ ទិញបាយទិញស្រាផឹកទៅតាមការ ឯមនុស្សទាំង ៣ នាក់នោះ ក៏យល់ព្រមតាមលោកតាសួស ក៏ឲ្យឧបដ្ឋាករៀបចំត្រមុងកន្ទេល គ្រឿងបរិក្ខាររបស់

ធុតង្គ បានហើយទើបនាំមនុស្សទាំង ៣ នាក់នោះ ចេញចាកស្រុកក្រោម ទៅកាន់ស្រុកលើ ឯតាសួសក៏ក្លែងខ្លួនធ្វើជាលោកធុតង្គដោយដែរ ដល់វេលាព្រឹកក៏ចូលទៅបិណ្ឌបាតក្នុងស្រុកតាមលំដាប់ផ្លូវ ឯពួកឧបាសកឧបាសិកានៅស្រុកក្រៅ កាលបើឃើញតាសួសនោះហើយ នឹកស្មានថាជាលោកសង្ឃធុតង្គក្រុមូលដោយសុចរិត ទើបនាំគ្នាដាក់បាត្រប្រគេនបច្ចុប្បច្ច័យផ្សេងៗ អ្នកខ្លះនិមន្តឆាកមហាបង្សុកូល អ្នកខ្លះនិមន្តឆាន់ធ្វើបុណ្យផ្សេងៗ តាមសទ្ធាអ្នកកាន់ព្រះពុទ្ធសាសនា តាសួសបានលាភសក្ការៈបរិបូណ៌ពោពាស ក៏ធ្វើជាសង្រួមឥន្ទ្រិយបែបភាពស្រគត់ស្រគំ រមទម្យ ពុំសូវនិយាយស្ដីអ្វីប៉ុន្មានឡើយ ឯមនុស្ស ៣ នាក់នោះ តែដើរទៅដល់ទីណា ក៏នាំគ្នានិយាយសរសើរគុណតាសួស ប្រាប់អ្នកស្រុកនោះថា លោកគ្រូយើងនេះ លោកវិសេសខាងផ្លូវក្នុងពេកណាស់ ទាំងទឹកមន្តក៏ពូកែសក្តិសទ្ធិ ចេះទាំងយិតមើលហួយមើលជោ៉ ក៏ចុតឆាប់តែលោកថាអ្នកសន្តោស មិនមានសេចក្ដីលោភទេ បើអ្នកណាត្រូវបិត្តលោកៗ ក៏ប្រោសឲ្យបានបានសម្រេចប្រយោជន៍គ្រប់ប្រការ ពួកយើង ៣ នាក់នេះ ក៏ឧស្សាហ៍ដើរតាមលោកម៉្លេះនេះ ព្រោះឃើញសិល្បវិជ្ជាការនេះមិនទែនណាស់ឯពួកមហាជនទាំងឡាយ កាលបើបានស្ដាប់ពាក្យអ្នកទាំង ៣ ស្រដីអួតតាសួសដូច្នោះហើយក៏ជឿតាម ទើបនាំគ្នានិមន្តតាសួសសូត្របូជាព្រះ

គ្រោះខ្លះ សូមមន្តខ្លះ សូមខ្សែក្រខ្សែបន្តោះខ្លះ តាសួសបានលាភសក្ការៈ បរិបូណ៌ច្រើនឡើង ៗ ដោយពួកអ្នកស្រុកគោរពរាប់អាន តែដល់ពេលយប់ស្ងាត់ ទៅតាំង៣នាក់ក៏ទៅលួចទិញស្រា ទិញបាយមកលៀងគ្នាក្នុងព្រៃ



តាមវិស័យ សើចលេងសប្បាយរៀងៗខ្លួន ។

ឯតាសួសនិងអ្នក ៣ នាក់ ក៏ប្រព្រឹត្តអាការៈយ៉ាងនេះរៀង ៗ ទៅ

តាមផ្លូវ លុះថ្ងៃ ១ នោះ តាស្លួសនាំគ្នាទាំង ៣ នាក់ដើរទៅដល់ភូមិ ១ ទើបចូលទៅកាន់ភូមិនោះ ហើយទៅអង្គុយក្រោមម្លប់ដើមពោធិ៍ខាងត្បូងភូមិនោះ ឯចៅ ៣ នាក់ក៏នាំគ្នាចូលទៅក្នុងភូមិ និយាយឃោសនា ប្រាប់អ្នកស្រុកថា លោកធុតង្គរុក្ខមូលលោកនិមន្តមកគង់នៅខាងត្បូងភូមិនោះឯង បើបងប្អូនញាតិសន្តានព្រៀងលានណា មានប្រាថ្នាដោយការអ្វី ៗ សូមអញ្ជើញយកទឹកតែស្កររសស្លាបារីទៅប្រគេនលោកចុះ លោកនិមន្តមកនេះ មិនមែនឥតប្រយោជន៍ទេ គឺនិមន្តមកប៉ងដើម្បីប្រោសសត្វបំបាត់សោកហើយ បើអស់លោកណាចង់បានខ្សែកខ្សែចង្កេះ ទឹងទឹកមន្តការពាររោគអាសន្នកម្មផ្សេង ៗ កំសូមអញ្ជើញទៅរកលោកដោយឆាប់ ៗ ចុះ

ឯបណ្ដាមហាជនប្រុសស្រី នៅទីភូមិនោះលុះឮថា លោកធុតង្គរុក្ខមូលវិសេសមកដូច្នោះហើយ ខ្លះក៏បានស្លាបារី ខ្លះក៏បានទឹកក្ដៅត្រជាក់ នាំគ្នាទៅរកតាស្លួស ដល់ហើយក្រាបថ្វាយបង្គំសួរទទួលពាក់ទាក់ដោយអាមិសបដិសណ្ឋារៈគ្រប់យ៉ាង ប្រគេនទឹកស្រង់ទឹកឆាន់ ស្លាម្លូកេសជ្ជៈតាមសទ្ធារៀង ៗ ខ្លួន ទើបសំពះសួរថា ៖

ព្រះករុណាម្ចាស់និមន្តមកពីស្រុកណា ?

ព្រះតេជព្រះគុណ !

តាស្លួសទទួលឆ្លើយថា ចំរើនពរអាត្មាភាពនេះនៅទីក្នុងទីក្រុងបេញ

មកផុតគង្គក្រុមលយូរវែងយូរឆ្នាំហើយ អាត្មាភាពនៅតែក្នុងព្រៃមិនដែលចូល ទៅកាន់ស្រុកភូមិណាទេញោម ! ទើបតែថ្ងៃនេះមានហេតុជាការមិនស្រួលនៅស្រុកភូមិញាតិញោមនេះ បានជាអាត្មាភាពខំខស្សាហ៍និមន្តមកនេះ ឯពួកអ្នកស្រុកនោះ លុះឮតាសួសថាដូច្នោះហើយ ក៏កើតសេចក្ដីសង្ស័យឡើងគ្រប់គ្នា ទើបនាំគ្នាសួរតបទៅវិញថា ៖

ករុណាម្ចាស់! បពិត្រព្រះគុណធ្ងន់ក្រៃ! មានពុទ្ធដីកានេះយល់ប្លែកពេកណាស់ ចុះលោកម្ចាស់យល់ហេតុភូមិយើងខ្ញុំនេះមិនស្រួលយ៉ាងណា ?

— ញាតិញោមអើយ ! អាត្មាភាពអង្គុយធម៌យប់មិញនេះ មានឃើញហេតុអន្តរាយ នឹងកើតមានដល់ញាតិញោមក្នុងភូមិនេះទាំងអស់គ្នា គឺអាត្មាភាពឃើញថាភូមិនេះនៅតែ ៧ ថ្ងៃទៀត នឹងមានអសនីបាត គឺអន្ទុះបាញ់មកត្រូវភូមិនេះដល់នូវសេចក្ដីវិនាសសាបសូន្យទាំងភូមិជាម្ដង ! អាត្មាភាពគិតទឹកអាណិតដល់ញាតិញោមទាំងអស់គ្នាណាស់ ! បានជាខំខស្សាហ៍មកនេះ ប្រាថ្នានឹងប្រាប់សេចក្ដីនោះឲ្យញាតិញោមបានដឹងខ្លួនជាមុន ថាបើញាតិញោមឯណាចង់ឲ្យរួចពីកាឡកិណ្ណីសេចក្ដីវិនាសនោះ ត្រូវតែរុះរើផ្ទះសំបែងចេញអំពីភូមិចាស់ ទៅតាំងនៅភូមិក្រៅជាថ្មីម្ដងទៀត នោះទើបរួចភ័យអំពីអសនីបាតនោះបាន ឯបណ្ដាមហាជនទាំងឡាយ

ៗនោះ លុះពុទ្ធតាសួរសថាដូច្នោះហើយ ក៏កើតសេចក្តីភិតភ័យ ទាំងអស់គ្នា ទើបតបវិញថា:

សូមទានករុណាម្ចាស់ ! បើដូច្នោះ សេចក្តីវិនាសនោះ នឹងមានដល់ពួកយើងខ្ញុំហើយឬ ? តែថាឲ្យពួកយើងខ្ញុំរុះរើផ្ទះសំបែងនោះ ចេញអំពីភូមិនោះទៅតាំងនៅភូមិថ្មីទៀត ជាការលំបាកពន់ពេកណាស់បើដូច្នោះ សូមករុណាម្ចាស់ នឹងមានឧបាយកលល្មមឧបទេសកែខៃសេចក្តីអន្តរាយអំពីអន្ទះនោះជាបានខ្លះឬទេ ?

— ឱញាតិញោមអើយ ! ចង់គិតកែខៃឧបទេសនោះ ប្រហែលជាបានមើលទៅ ! ចាំអាត្មាភាពអង្គុយធមិសាកមើលសិន ថាហើយតាសួរក៏តាំងអុជទៀនធូបហើយតាំងសមាធិ អង្គុយធ្មេចភ្នែកបន្តិចបើកភ្នែកឡើងថា បានញោម! មិនអីទេ តែញាតិញោមត្រូវខាតដើមទុនខ្លះទើបអាចធ្វើបាន .....

— ករុណាម្ចាស់មិនអីទេ ទោះបង់ខាតធនធានប៉ុន្មានៗ ក៏មិនថាទេធ្វើម្តេចឯងដល់សេចក្តីវិនាសហើយ· សូមនិមន្តលោកគ្រូម្ចាស់បង្គាប់មកចុះ

— ឱ! ញាតិញោមអើយ អាត្មានេះជាសង្ឃផងនឹងបង្គាប់បញ្ជាទៅ ក៏ហាក់ដូចជាមិនគួរនឹងគេឯងទជាសមណ:នោះសោះ ដ្បិតកើតអន្ទះនោះ តាមបាលីថា អសនី គឺថា អសុភ ប្រែថា យក្ខខ្មោចៗ

នោះវាគាប់ចិត្តតែនឹងស្រាបាយ សាច់ញាំក្ងាមាន់ស្ងោរ រៀបបូជាពលិ-ការវា ហេតុនោះបានជាអាត្មាតាល់ណាស់ ព្រោះឯងជាលោកសន្យ...

— ករុណាម្ចាស់ កុំព្រួយព្រះទ័យឡើយ ទិមន្តបង្គាប់មកចុះ ពួកយើងខ្ញុំនឹងធ្វើតាម

— ឱ! ញាតិញោមអើយ... ត្រូវធ្វើរោងពិធី ១ ខ្នងនៅក្រៅភូមិ ហើយឲ្យធ្វើជាពជវតិ ទង់ ឆត្រ ស្លាធម៌ បាយសី ជម ធារ គ្រឿងបំភាបបន្ថែមផ្សេងៗ យកទៅតាំងនៅរោងពិធី...

មនុស្សទាំងឡាយ ក៏នាំគ្នាធ្វើតាមពាក្យតាសួសនោះសព្វគ្រប់ប្រការ ឯតាសួសក៏នាំគ្នាទាំង ៣ នាក់ចូលទៅក្នុងរោង ហើយយកអំបោះ ចងព័ទ្ធសីមា ៧ ជាន់ ហើយប្រាប់អ្នកស្រុកថា ញាតិញោមទាំងអស់នេះ សុទ្ធសឹងតែមនុស្សមានគ្រោះធំ ត្រូវតែនៅក្រៅរោងពិធីនេះ តាសួសថាហើយ ទើបសរសេរសំបុត្របិទនៅមាត់ទ្វារនោះ ថា៖

— កុំឲ្យនរណាចូលមកក្នុងរោងពិធីនេះឡើយ ថាបើនរណាអាចហ៊ានកាត់អំបោះសីមាកន្ទងចូលមកក្នុងរោងពិធីនេះហើយ អ្នកនោះនឹងទៅជាផ្កុតឈើ ស្លាប់កើតវិបត្តិផ្សេងៗ បណ្ដាអ្នកស្រុកទាំងនោះក៏ធ្វើតាមតាសួស ហាមទាំងអស់ នាំគ្នាហាមកូនចៅក្មេងតូចធំ កុំឲ្យចូលទៅក្នុងរោងពិធីនោះៗ

ឯតាសួសបានឱកាសស្ងាត់ហើយ ក៏នាំគ្នាទាំង ៣ នាក់ស៊ីបាយផឹក

ស្រាតាមអំពើពុតអាក្រក់ លុះស្រវឹងស្រាខ្លាំងក៏តាំងនិយាយគោកគាកៗ ប្រកែកគ្នាទៅវិញទៅមកគឹកកងរំពងក្នុងរោងនោះ លុះនៅដល់បាន ២-៣ ថ្ងៃ មានកុមារម្នាក់អាយុ ១៤ ឆ្នាំ ឈ្មោះចៅសេក ក្មេងនោះវាទៅឃ្វាលក្របីនៅវាលស្រែ ដល់ពេលថ្ងៃល្ងាចត្រជាក់ ចៅសេកវាដេញក្របីទៅផ្ទះ បរទៅខាងរោងពិធីនោះ បានឮសំឡេងអ្នកទាំង ៤ នាក់ ផឹកស៊ីប្រកែកគ្នាគោកគាកដូច្នោះហើយ ចៅសេកគិតថា សំឡេងយ៉ាងនេះ ទំនងជាមនុស្សស្រវឹងស្រា យ៉ាងជាលោកសង្ឃនោះផឹកស្រាទេដឹង បើដូច្នេះគួរអញទៅលបមើលអេះ ដើម្បីបញ្ជាក់ការនោះឲ្យជាក់ច្បាស់សិន ទោះវាធ្កតប្តូឈើទាប់យ៉ាងណាក៏តាមចុះ អញប្រថុយលមើល គិតហើយ ក៏ដើរលបចូលទៅដល់ប្របជញ្ជាំងរោង ហើយលួចបើកស្លឹកត្នោតដែលបាំងនោះគន់មើលទៅក្នុងរោង ក៏ឃើញតាជែង ៤ នាក់នោះ វាអង្គុយជិតគ្នា ស៊ីបាយផឹកស្រាដោយអំពើពុតអាក្រក់ ចៅសេកឃើញហើយក៏នឹកថា យី! តាជែងចាស់នេះ ផឹកស្រាស៊ីបាយល្ងាចទេតើ! ពុទ្ធោៗ! ធម្មោៗ! សង្ឃោៗ! នុ! ម៉ែឪអញទៅរៀកាពួកនេះធ្គត ទទេ ទាំងអ្នកស្រុកក៏ជឿចុះចូលវា ឲ្យវាបញ្ឆោតអស់ទាំងអ្នកស្រុកទៅហើយ បើដូច្នោះគួរអញទៅប្រាប់ម៉ែឪអញឲ្យគាត់បានដឹងផង គិតហើយក៏ដើរថយចេញម្ម៉ា រត់ត្រង់ទៅផ្ទះ បានឃើញម្ដាយនៅលើផ្ទះ

ចៅសេកក៏ស្រែកប្រាប់ទៅថា ម៉ែៗ លោកអ្នកមានគុណធ្ងន់ក្រៃ! ម៉ែឯងទៅជឿអីលោកសង្ឃពុតត្គនោះ មិនពិតជាលោកសង្ឃល្អទេ វាក្លែងក្លាយទេម៉ែ ខ្ញុំបានឃើញវាផឹកស្រាស៊ីបាយល្ងាចអំបាញ់មិញនេះឯង ៗ

ឯនាងជាម្ដាយបានឮពាក្យកូនប្រាប់ដូច្នោះហើយ ក៏ពុំមានសតិសម្បជញ្ញៈ នឹងត្រិះរិះឲ្យច្បាស់លាស់ ដោយជឿពាក្យលោកតាសួសថានរណាកាត់ស៊ីមាចូលក្នុងរោងពិធីលោកអ្នកនោះនឹងធ្លាក់ប្រាកដ ទើបកើតភិតភ័យតក្កមាហើយសួរថា កូន! កូន ៗ ឯងចូលទៅក្នុងរោងពិធីលោកឬអី? កូនឆ្លើយថា បាទ បាទខ្ញុំលបលួចចូលទៅឃើញ វាកំពុងតែផឹកស៊ីទាំង ៤ នាក់ណាម៉ែ ម្ដាយថា ឱ! កូនអើយលោកបានហាមប្រាមទាំងអស់គ្នា ថាកុំឲ្យនរណាចូលទៅក្នុងរោងពិធីលោក ឥឡូវកូនឯងចូលទៅនោះ ត្រូវដូចពាក្យលោកថា អ្នកណាចូលហើយ អ្នកនោះនឹងធ្លាក់មិនខាន ឥឡូវកូនឯងធ្លាក់ហើយតើកូន គួរអីទៅថាលោកសង្ឃផឹកស្រានោះ លោកជាអ្នកដើរធុតង្គកម្មលវិសេសណាស់ ចៅសេកប្រកែកថា ម៉ែឯងមិនជឿខ្ញុំទេឬ? ខ្ញុំបានឃើញច្បាស់នឹងភ្នែកហើយ អាផែនទាំង ៤ នាក់នោះវាមកក្លែងបញ្ឆោតគេយកលាភទេ អ្នកណាទៅជឿវាគង់នឹងខូចខ្លួនមិនខាន ឯនាងម្ដាយមិនស្ដាប់ ចេះតែថាអាឯងទៅចូលក្នុងស៊ីមាលោក វាធ្លាក់មែនហើយ ឯបណ្ដាពួកញាតិនៅជិតខាង បានឮចៅសេកនឹងម្ដាយប្រកែក

គ្នាដូច្នោះហើយ សឹងគោឡាឡើងទៅសួរថា ម្ដេចចៅសេកវាទៅចូលក្នុងសីមាលោកនោះឬអី? នាងម្ដាយក៏ប្រាប់ទៅថា អើងអឺយ វាចូលទៅក្នុងសីមាលោក ឥឡូវវាឆ្កួតណាស់ ទៅតាំងតែដេរលោកសង្ឃនោះផ្សេងៗ

ឯពួកញាតិ ក៏តាំងស្ដីបន្ទោសចៅសេកថាឆ្កួតមែនហើយ ធ្វើម្ដេចនឹងរកគ្រូឯណា នឹងមើលបាន ឯចៅសេកឮពួកញាតិគេស្ដីបន្ទោសដូច្នោះហើយ ក៏ខឹងណាស់ តាំងដេរផ្ដាសាពាសទៅ ដល់ប្រកែកនឹងគេមិនឈ្នះ វាក៏យំស្រែកផងព្រោះដោយសារក្មេង ឯពួកញាតិនឹងរឹតតែជឿថាចៅសេកឆ្កួតមែន គឺពីដើមគ្រាន់តែថាលោកសង្ឃផឹកស្រា ឥឡូវខ្លាំងតាំងយំដេរគេដេរឯងតែផ្ដាស មិនស្គាល់ចាស់ក្មេងផង ឯនាងជាម្ដាយនោះ ក៏ភិតភ័យខ្លាំង ទើបរត់ទៅឯកោនពិធីលោកតាសួស ដល់ហើយស្រែកហៅទៅថា៖

ឱ! ករុណាម្ចាស់ សូមមេត្តាប្រោសសត្វបំបាត់សោក ! សូមតាននិមន្ត! ចេញមកខាងក្រៅពេលសិន ដ្បិតសត្វកើតវិបត្តិហើយព្រះគុណម្ចាស់ ឯតាសួសឮនាងសិកានិមន្តចេញដូច្នោះក៏ស្ទុះប្រញាប់ជូតមាត់ជូតកស្អាកហើយ តាំងគ្រងចីវរជាបរិមណ្ឌល ពាក់ផ្ដុំកាន់ឈើច្រត់ ដើរលបៗចេញមកខាងក្រៅហើយសួរថាកើតអីញោម បានជាភិតភ័យរលះរលាំងយ៉ាងនេះ? នាងសិកានោះអង្គុយលុតជង្គង់ប្រណម្យដៃ ទូលថាករុណាម្ចាស់!

ឥឡូវនេះចៅសេកកូនខ្ញុំករុណាវាចូលមកក្នុងសីមាលោកម្ចាស់ ឥឡូវកើតទៅជាឆ្កួតពុំដឹងអ្វីសោះ ចេះតែយំស្រែក ដេរគេឯងពាសទៅដេរត្រូវទាំងលោកម្ចាស់ផង ។

តាសួសឆ្លើយថា អើញោម អាចក្តីបានហាមហើយ ថាកុំឲ្យប្រហែស ឲ្យហាមកូនហាមចៅកុំឲ្យវាចូលមកក្នុងសីមាពិធីនេះ ក្រែងវាកើតហេតុ ឥឡូវមែន ៗ ដូចពាក្យអាចក្តីថា ចុះឥឡូវនេះវានៅឯណាកូនញោមនោះ?

— ករុណាម្ចាស់ វានៅឯផ្ទះខ្ញុំករុណាឯនោះ

— អើបើ ដូច្នោះ ញោមទៅនាំខ្លួនវាមកឯរោងពិធីនេះ អាចក្តីនឹងមើលរោគឆ្កួតនោះណាញោម នែញោមពាក្យចាស់លោកថា:

បន្លាមុត តោងយកបន្លាដុស ...
ទឹកចូលត្រចៀក តោងយកទឹកចាក់ ...
ត្រូវកំចាត់សត្រូវដោយសត្រូវ
ឲ្យទ្រព្យដែលត្រូវដល់ចិត្តវា
ដូចបន្លាដែលមុតក្នុងបាទា
យកបន្លាដូចគ្នា ដុសទើបបាន ។

រោគឆ្កួតកើតមកពីរោងពិធីនេះឯង តោងញោមយកមករក្សាឯរោងពិធីនេះ ទើបជាសះស្បើយទៅបាន ឯនាងសិកានោះក៏សំពះលាតាសួស វិលទៅ

ពឹងបងប្អូនប្រុសៗ ៣-៤ នាក់ឲ្យជួយចាប់យកខ្លួនចៅសេក មកប្រគល់ឲ្យតាស្នួស ឯចៅសេកនោះត្រូវគេមកចាប់ដឹកនាំទៅផ្លូវច្បោះ ក៏រឹងរិតតែខឹង ទឹងពួកញាតិតាំងបម្រះនទៀលជេរគេជេរឯង ហើយយំស្រែកទៅតាមតាសាក្រូងតែធន់ពុំបានទឹងកំលាំងមនុស្សច្រាស់ៗ គេក៏នាំគ្នាចាប់សែងពត នាំទៅដល់រោងពិធីនោះ ឯតាស្នួសក៏បបួលគ្នាទាំង ៣ នាក់ចេញមកខាងក្រៅរោង ហើយទទួលយកចៅសេកចូលទៅក្នុងរោងតាស្នួប ៗ ប្រាប់ទៅថា: ញោមទាំងអស់គ្នាស្ទួតែជាអ្នកមានគ្រោះថ្នាក់ទឹងនៅជិតរោងពិធីពុំបាន ក្រែងខ្មោចព្រាយអសនីនោះវាចូលរូបអាត្មានឹងស្រោចទឹកមន្តចៅសេកហើយ ខ្មោចដែលនៅក្នុងរូបចៅសេកវាខឹងស្រែកជាខ្លាំងពុំខាន បើផ្លូវច្បោះចូលញាតិញោមទាំងអស់គ្នាចៀសចេញទៅផ្ទះវិញឲ្យឆាប់ៗ កុំនៅយូរ ក្រែងខ្មោចវាចូល ឯរូបចៅសេកនេះមិនអីទេ តែស្អុកខាងស្អុកគង់ខឹងជាពុំខាន ឯពួកញាតិចៅសេក ឮតាស្នួសថាផ្លូវច្បោះហើយ ក៏នាំគ្នាសំពះលាតាស្នួសវិលទៅផ្ទះទីទៃ ៗ ទៅ ឯតាស្នួសចូលទៅក្នុងរោងពិធីហើយឲ្យគ្នា ៣ នាក់នោះចងចៅសេកភ្ជាប់ទឹងសសររោង តាំងការពារគផ្ដៅម្នាក់មួយ ៗ គ្រប់ទាំង៤នាក់ ហើយក៏ហែងសួរចៅសេកថា: អើអាសេកអាឯងថា ឃើញពួកអញស៊ីបាយផឹកស្រាមែនឬដូចម្ដេច?

ចៅសេកឆ្លើយថា អើមែនខ្ញុំឃើញលោកតាឯង ផឹកស្រា ស៊ីបាយល្ងាច ព្រាកដទាំង ២ នាក់មែន ពួកទាំងនោះក៏កើតកោសោ ហើយវាយចៅសេក ២-៥ រំពាត់ ចៅសេកក៏ស្រែកយំដោយសំឡេងខ្លាំង ទាំង ២ នាក់



ក៏សួរសាកទៀតថា ដូចម្តេចអាសេកអាឯង ថាពួកយើងផឹកស្រាមែន ឬ ដូចម្តេច ?

– អើ អាឯងផឹកស្រាមែន អញឃើញច្បាស់នឹងភ្នែកអញហើយ អា ៤ នាក់គំរើរតែវាយខ្ទាំងឡើង ៗ លើសមុន ចៅសេកបានដល់នូវសេចក្ដីទុក្ខវេទនាឈឺចាប់ពន់ពេកណាស់ ដល់ក្រោយទើបគិតថា ឱ ! អញនេះ ជាមនុស្សក្មេងម្នាក់ឯង គេឆ្កួតពេញទាំងស្រុកទៅហើយ តែឯងមិនធ្វើឆ្កួតតាមគេនោះ អាដែងពួកនេះ វាមុខជាវាយអញដល់នូវសេចក្ដីស្លាប់ពុំខានឡើយ ។

ណ្ហើយចុះគោងធ្វើជាឆ្កួតតាមវាទៅចុះទើបរក្សាខ្លួនសុខបាន ចៅសេកគិតដូច្នោះហើយទើបលើកដៃសំពះតាស្លួស ហើយសារសព្វប្រាប់ទៅថា:

ករុណាម្ចាស់ ខ្ញុំករុណានេះឆ្កួតពិតមែនហើយសូមទានប្រោសអត់ទោសខ្ញុំ ៗ ឆ្កួតមិនដឹងខ្លួនមិនដឹងប្រាណទេព្រះគុណ បានជាថាព្រះគុណផឹកស្រានោះ គឺព្រះគុណពុំមែនឆាន់ស្រាទេ ខ្ញុំឆ្កួតមែនហើយ ឥឡូវខ្ញុំដឹងខ្លួនជាសះស្បើយហើយ រាងចាលហើយ ពីនេះទៅទៀតខ្ញុំពុំថាព្រះគុណផឹកស្រាទេទាន

– អើបើ ឯងលែងថាអញផឹកស្រារាងចាលហើយ អញក៏លែងវាយឯង ៗ តែត្រឹមនេះ ករុណា ខ្ញុំករុណាលែងថា ព្រះគុណឆាន់ស្រាទៀតហើយ អំពីថ្ងៃនេះតទៅបើដូច្នោះមែន អញក៏លែងវាយឯងដែរ បើឯងនៅតែថាអញ ៗ ក៏វាយឯងទាល់តែស្លាប់ ថាហើយតាស្លួស ក៏ឲ្យ

ស្រាយបំណាងចៅសេកឃាត់ខាំងចៅសេកមិនឲ្យចេញទៅខាងក្រៅពេន ពិធី ឯចៅសេកសោតទាល់ចំណោះ ក៏នៅបំរើកា ៤ នាក់នោះទៅតាមអធ្យាស្រ័យក៏ លុះថ្ងៃគំរប់ ៧ ជាពេលយប់ស្ងាត់ ចៅសេកដេកលក់ទៅ អាដៃន ៤ នាក់នោះ តាំងរើគ្រឿងពិធីយកប្រាក់សំពត់ផ្ដិល ជើងពានរៀបជាសម្ពាយហើយនាំគ្នាលបរត់ចេញចាកស្រុកនោះ ទៅកាន់ស្រុកឯទៀតទៅ លុះដល់វេលាព្រឹកចៅសេកភ្ញាក់ឡើង ស្រាប់តែស្ងាត់ឈឹងទាំងពេនមើលទៅគ្រឿងតាំងពិធីនោះក៏បាត់អស់រលីងគ្មានសល់ដល់តិចតួចឡើយ ចៅសេកក៏ដឹងថាតាសួស លួចរបស់ទ្រព្យរត់ទៅអស់ហើយ ទើបចៅសេកដើរចេញចាកពេន ចូលទៅផ្ទះខ្លួន ឯបណ្ដាញាតិមិត្រឃើញចៅសេកដើរមកផ្ទះហើយ ក៏សួរថា ដូចម្ដេចទៅជីសេកអើយ ! ពេលនោះបានស្រាកស្រាលធូរខ្លួនប្រាណខ្លះហើយឬដូចម្ដេចទៅ ?

ចៅសេកក៏តបថា នៅឡើយទេ តែថា ឥឡូវនេះ អំពើបិគួតនោះវានៅលើអ្នកស្រុកទាំងអស់គ្នា អើឯង ៗ ជាសោះគេឆ្កួតពេញទាំងស្រុក ក៏ត្រឡប់ជាឯងឆ្កួតវិញ អើម៉ឹង មារ យាយតា ទាំងអស់គ្នាទៅជឿអាដៃន ៤ នាក់នោះទុកជាគ្រូ ថាលោកពុតគ៌ក្រមូលវិសេសណាស់ ឥឡូវគ្រឿងប្រដាប់ដែលតាំងពិធីពូការនោះ លោកពុតគ៌ទោះបន្ទុំផាកយកទៅអស់ហើយ ថាហើយចៅសេកក៏ដើរដម្រង់ទៅផ្ទះទៅ ។

ឯបណ្ដាអ្នកស្រុកបានឮពៅសេកថាដូច្នោះហើយ ខ្លះក៏សង្ស័យថាក្រែងពិតដូចពាក្យពៅសេកថាឬ? ទើបនាំគ្នាទៅឯរោងពិធី ស្រាប់តែឃើញស្ងាត់ឈឹងសូន្យ ក៏ចូលទៅក្នុងរោងយល់របស់ទ្រព្យខ្លួននោះវិនាសអស់ទៅដោយដៃមនុស្សប្រែដទាំង ៤ នាក់ដូច្នោះហើយ ទើបនាំគ្នាមកកាន់ផ្ទះរៀង ៗ ខ្លួនវិញ កើតវិប្បដិសារីរលឹកទោសខ្លួនឃើញថាជាមនុ-ស្សឥតបញ្ញា ឆ្កួតអស់ទាំងស្រុក គ្មានអ្នកណាជាសោះ ពៅសេកគ្នាជាសោះ ទៅថាគ្នាឆ្កួត ឱ! ពុទ្ធោ អរហំ ក្បាលកាំងកន្ទុយស្វារ អាចម៍គណ្ឌុរកន្ទុះកព្រោ ៗ

និទានពីរឿងតាស្មួសអស់សេចក្ដីតែប៉ុណ្ណោះ; ចាប់តាំងពីនេះទៅទៀត និយាយពីឈ្មោះលោកគ្រូអ៊ិកអី ៗ នេះកាលពីដើមឈ្មោះលោកតាស្មួស ដល់មករឿងខាងចុងទើបគេឲ្យឈ្មោះលោកគ្រូអ៊ិកអីទៅវិញ សូមលោកអ្នកអាន អ្នកស្ដាប់ទាំងឡាយ គួរចូលចិត្តតាមរឿងខាងក្រោមដូចតទៅនេះ!

## តត្រាយំ វត្ថុ=

រឿងរ៉ាវនេះ មានក្នុងផ្ទៃនោះថាលោកតាស្មួសនឹងសិស្ស ៣ នាក់នាំគ្នារត់ចេញពីទីនោះទៅ បានទៅដល់ភូមិ ១ ឆ្ងាយរំលងស្រុក ១ ស្រុក ២ ជិតដល់ទៅទីក្រុង តាស្មួសនៅយូរ ៗ ទៅ រកវត្ថុអ្វីបរិភោគពុំសូវបាន

ពេញលេញដូចកន្លងពេលមុន ទើបបង្គាប់កូនសិស្ស ៣ នាក់ថា ម្នាល អា ៣ នាក់! អាឯងចូរធ្វើតាមពាក្យអញ ទើបបានវត្ថុស៊ីបាយសប្បាយចិត្ត មើលទៅពួកយើង បើគាន់តែឯងមិនបែបហ្នឹង មុខជាស្វិតពោះពុំខាន ដូចពាក្យយើងថា:

វិន័យក្រៀមផ្កាក តិរេកស្អកពោះ វិន័យគ្មានយស ព្រោះតិរេក ។

បដិសំខាយោនិសោ ពូតពម បាយកកសម្ផូម ត្រិប្រាខ្វាញ់ខាប់
លើកពមប្រញាប់ តតិយម្បិ ។

ពួកយើងកុំបាច់គិតអ្វីច្រើន គិតតែពីស៊ីដេក ។ កុំបាច់គិតខ្វល់ខ្វាយ ពួកយើងថាម៉ាយរស់ដោយមានក្បួន អ្នកមានព្យាយាមប្រាជ្ញាមាំមួន បានបេះចាំក្បួន បានជាការអ្វី?... ។

បើដូច្នេះ ចូរឯងទាំង ៣ នាក់ធ្វើតាមពាក្យអញ

— ករុណាលោកគ្រូ មិនអីទេ.....

ឯងទាំង ៣ នាក់ ត្រូវទៅលបមើល នង្គ័ល រនាស់ ក្របី-គោគេ ដែលគេយកទៅទុកដាក់នៅវាលស្រែ ឯងទាំងអស់គ្នា ចូរទៅយករបស់ទាំងនោះ យកទៅលាក់ឲ្យបាត់ ឲ្យឆ្ងាយពីកន្លែងបន្តិចទៅ ហើយឯងទាំងអស់គ្នា មកប្រាប់អញឲ្យដឹងសព្វគ្រប់អស់ហើយ ឯងដើរទៅនិយាយអួត

អាងប្រាប់អ្នកស្រុកឲ្យគេជឿ ហើយគេមករកអញទាយ កាលបើអញទាយទៅត្រូវ គេនឹងយកបាយសម្លុយកាក់មកបូជាអញហើយ យើងទាំងអស់គ្នា មុខជាបរិបូណ៌គ្រប់គ្រាន់ ស៊ីបាយសប្បាយកាយសប្បាយចិត្តពុំខាន កូនសិស្សតាំងធ្វើតាមពាក្យលោកតាសួស ឯអ្នកស្រុកស្រែ ខ្លះបាត់ងង្គ័ល រនាស់ ខ្លះបាត់គោ ខ្លះបាត់ក្របី ដល់ឮថាលោកតាសួសល្បីឈ្មោះពូកែខាងទាយ ពួកគេទាំងនោះ ចូលមករកលោកតាសួសឲ្យទំនាយឲ្យតាមរបស់រៀង ៗ ខ្លួន

ឯតាសួសក៏ចាប់យកដីស នឹងក្តារឈ្នួន មកគូសខ្វែងចុះ ខ្វែងឡើងរួចហើយ ទើបកាប់លេខថា ៖

ប៉កអ៊ិកប៉កអី ដើរក្តាមប្រាំបី
បេកផុតជំឡូងស្វារ . . .
អត្តខ្លួនប្រាណ ទៅណាមិនបាន
នៅក្នុងទីនោះ . . . . .
អត្តខ្លួនអាត្មា ពុំបាត់ទៅណា
នឹងរកឃើញវិញ . . . . . ៗ

ទើបទំនាយថា : ញោម គោនឹងក្របី ញោមឯងរកមើលក្នុងព្រៃថ្លុកត្រពាំងខាងជ្រិចស្រែ ឃើញហើយមិនបាត់ទេ ឯនង្គ័លនឹងរនាស់ នៅក្នុងត្រពាំង

ទឹកនោះដែរ ចុះពវរកមើលកង្ទឹកទៅឃើញហើយ ៗ

ពួកគេទាំងអស់ ក៏ទៅរកមើលតាមពាក្យលោកតាសួស ក៏ឃើញពិតប្រាកដមែន គេក៏ជឿតាមស្ញុងចិត្តគំនិតទាំងអស់គ្នា ឯកូនសិស្ស ៣ នាក់ តាំងពីថ្ងៃនោះមក បេះតែដើរស្វែងរកលបលួចលាក់ទ្រព្យរបស់អ្នកស្រុក ឲ្យគេមករកលោកតាសួស ឯតាសួសបេះតែទំនាយទៅត្រូវចំទាំងអស់ឥតមានខុស ឈ្មោះលោកតាសួសក៏ល្បីឮសុសសាយពេញទាំងស្រុក កាលថ្ងៃ១នោះ ពួកអ្នកស្រុកគេចង់ដឹងវិជ្ជាការលោកតាសួស គេគិតគ្នាមករកលោកឲ្យទំនាយឲ្យ ថាថ្ងៃស្អែកនេះ ភ្លៀងឬមិនភ្លៀង គេចង់ដឹងគេសាកល្បងមើល ទើបចូលមករកតាសួសឲ្យទំនាយឲ្យ ឯតាសួសកាលបើអ្នកស្រុកគេមករកឲ្យទំនាយពីភ្លៀងមិនភ្លៀងដូច្នោះ ក៏ទាល់គំនិតគិតមិនលេច ទើបប្រាប់គេថា ណ្ហើយញោម ពេលនេះអាត្មា ហាក់ដូចជាពុំស្រួលកាយសប្បាយចិត្តសោះ ចាំពេលក្រោយសិន ម្យ៉ាងទៀតការទំនាយពីភ្លៀងមិនភ្លៀងនេះ ជាការលំបាកណាស់ លុះណាតែគិតផ្ចង់តាមលេខនេះសាចុះសាឡើង ចំនួន១យប់ ទើបអាត្មាហ៊ានទាយទៅប្រហែលជាត្រូវខ្លះ បើដូច្នោះ ចូរញាតិញោមទាំងអស់គ្នាអញ្ជើញទៅផ្ទះសិនចុះ ចាំថ្ងៃក្រោយ ៗ ពួកអ្នកស្រុកក៏ធ្វើតាមពុំហ៊ានរឹងទទឹងឡើយ ៗ

ឯតាសួសនឹងសិស្ស៣នាក់អង្គុយជុំគ្នាស៊ីផឹកពុំបានសប្បាយដូចពេលមុនឡើយ ព្រោះកើតទុក្ខ ជំនុំជម្រះគ្នាពីទំនាយកៀងឬមិនកៀង អ្នកតាំង៤កំពាល់គំនិតគិតមិនលេច មុជមិនជ្រៅ ទៅមិនឆ្ងាយ កើតបិត្តក្ដៅក្រហាយ ទើបនាំគ្នារត់ចេញទៅតាំងយប់ ពេលដែលលបរត់ចេញទៅនោះគ្រាន់តែដើរទេ តែដើរបែបលឿនរហ័ស ព្រោះភិតភ័យតែរៀងៗខ្លួនៗ ប្អូនជាពេលនោះ ពួកអ្នកស្រុកផ្អើលគោឡានឹងពួកចោរព្រៃ វាចូលមកប្លន់អ្នកស្រុកយកគោក្របី ឯតាសួសនឹងសិស្ស៣នាក់ឮសូរស័ព្ទខ្លាំង



ដូច្នោះ រឹងរិតតែភ័យខ្លាំងឡើង ឯសិស្ស៣នាក់រត់ប្រាយទៅចោល

តាសួស ៗ រត់ទៅតាមក្រោយពុំសូវលឿន ព្រោះខ្លួនចាស់ដកដ្ហួលប្រញាប់ ប្រឹងរត់បន្តិចទៅដល់ត្រពាំងទឹក លោកតាសួសក៏ទាក់ជើងវល្លិ៍ដួលដេក នៅក្បែរត្រពាំងទឹក ឯត្រពាំងទឹកនោះមានសត្វកង្កែបហ៊ឹង វាយំឆ្លើយឆ្លងគ្នា តាសួសគិតថា អើអញ ប្រហែលជារួចខ្លួនមើលទៅ ស្អែកនេះពិតជាភ្លៀងហើយ បានជាសត្វទាំងអស់នេះ វាយំឆ្លើយឆ្លងគ្នា បើដូច្នោះអញគិតត្រឡប់ទៅវិញទើបស្រែកប្រកូកហៅសិស្ស ៣ នាក់ឲ្យត្រឡប់វិលវិញ តាសួសនឹងសិស្ស ៣ នាក់នាំគ្នាមកនៅទីកន្លែងដើមវិញ ពុំមានអ្នកណាដឹងសោះ ព្រោះយប់ស្ងាត់ណាស់ មកដល់ហើយតាសួសប្រើសិស្ស ៣ នាក់ឲ្យទៅដាស់អ្នកស្រុកទាំងយប់មកកុំឲ្យខាន តែខានអាបក្តីលែងទំនាយឲ្យទៀតហើយ ឯសិស្ស ៣ នាក់ក៏ធ្វើតាម ទៅហៅអ្នកស្រុក ៗ ក៏បបួលគ្នីគ្នាមកចំនួន ២០៣០ នាក់មកដល់អង្គុយនិយាយរៀបរាប់តាមហេតុដើម តាសួសទាញដីសក្តារឈ្នួនមកខ្វែងចុះឡើង រៀបរាប់ដូចពេលមុនទើបទំនាយថា នែញាតិញោម ! ទាំងអស់គ្នា ស្អែកនេះប្រុងប្រយ័ត្នឲ្យមែនទែន ព្រោះមានភ្លៀងធ្លាក់ជាប្រេនមេមកលើស្រុកភូមិញាតិញោមបើរៀបចំរបស់អ្វី ៗ ក៏រៀបចំឲ្យស្រេចបាច់ទៅ ថ្ងៃស្អែកនេះ ជាថ្ងៃមានភ្លៀងធំ ឯអ្នកស្រុកក៏ជឿតាមត្រឡប់ទៅផ្ទះវិញ បានហាមប្រាមគ្នីគ្នាអស់ទាំងស្រុក លុះថ្ងៃស្អែកឡើងភ្លៀងក៏ធ្លាក់មកមែន ដូចពាក្យលោកតាសួសទាយ ឯ

អ្នកស្រុកក៏រឹងរិតតែជឿ ហើយជឿទៀត ជឿនោះពុំស្អាត ជឿអស់ទាំងអ្នកស្រុក ជឿនោះមិនសាប់ ជឿនោះមិនសុខ អស់ទាំងអ្នកស្រុកមកជឿមនុស្សកូត ៗ ឈ្មោះលោកតាសួស ក៏ល្បីល្បាញដល់ព្រះរាជាដែលសោយរាជ្យក្នុងព្រះនគរ ព្រះរាជាចង់ដឹងមន្តវិជ្ជាការលោកតាសួសនោះដែរ ។

ចួនជាពេលនោះ ព្រះរាជាបាត់ប្រាក់ជាច្រើន ប្រហែលជាពីរការុងអង្ករ ឯប្រាក់នោះ គឺអាមាត្យម្នាក់ឈ្មោះ (អាប្រាណ) វាលួចយកទៅលាក់ ព្រះរាជាទ្រង់ចាត់អាមាត្យម្នាក់ឲ្យមកនិមន្តលោកតាសួសយកទៅ ដើម្បីទំនាយឲ្យឃើញប្រាក់ អាមាត្យបាននិមន្តលោកតាសួសយកទៅតាមបង្គាប់ ដល់ហើយ ព្រះរាជានិមន្តលោកតាសួសឲ្យចូលទៅក្នុងបន្ទប់ ១ យ៉ាងស្ងាត់ ប្រគេនបង្ហិនឆាន់ស្រួលបួលចាំដល់ពេលល្ងាច ទើបនិមន្តលោកឲ្យទំនាយ ឯតាសួសមានសេចក្តីភិតភ័យខ្លាំងលើសមុន គិតថាឱ! អញស្លាប់ស៊ក្នុងពេលនេះហើយមើលទៅ គិត ១ គិត ២ ក៏នៅតែពុំទាន់ជាប់ស្រេច ឯអាមាត្យម្នាក់ឈ្មោះអាប្រាណនោះ វាដើរក្រឡឹងចុះក្រឡឹងឡើង ព្រោះវាភ័យខ្លាំងណាស់ គិតនឹងចូលមករកលោកតាសួសឲ្យជួយវា កុំឲ្យទាយចំឈ្មោះវា តែចំឈ្មោះអញៗ មុខជាស្លាប់ក្នុងពេលនេះមិនខាន អាប្រាណនោះវាមិនទៅណាឆ្ងាយពីលោកតាសួសសោះ ព្រោះវាប្រុង

តែបដើរទឹងតាស្លួស ឯតាស្លួសគិតសព្វគ្រប់ទៅមិនដឹងជាទៅផ្លូវណា ទើបបញ្ចេញវាចាថា ៖

ណ្ហើយចុះ អាខ្លួនប្រាណ មួយប៉ុណ្ណេះស្ដាយវាធ្វើអ្វី បើស្លាប់ក៏ស្លាប់ទៅចុះ តាមយថាកម្មអញ ឯអាប្រាណ បានត្រូវជ្រោះ ស្លាប់ពុំបានត្រង់ខ្លួនត្រូវតែត្រង់ប្រាណមួយម្នាក់ប៉ុណ្ណោះ ក៏នឹកស្មានថាអញស្លាប់មើលទៅព្រោះលោកតាស្លួសថា អាប្រាណ ស្លាប់ក៏ស្លាប់ទៅចុះនេះពិតជាឈ្មោះអញក័យខ្លាំងណាស់ ទើបចូលទៅក្រាបក្រោមបាទាលោកតាស្លួស អង្វរករថាកុំឲ្យតែបញ្ចេញឈ្មោះខ្ញុំករុណាថាលួចប្រាក់ ឯតាស្លួសបានពិតប្រាកដថាឈ្មោះអាប្រាណលួចយកប្រាក់ទៅ ។ លុះដល់ពេលល្ងាចព្រះកជានិមន្តតាស្លួស ។ ក៏ចាប់យកដីសទឹងក្តារឈ្នួនពីក្នុងថង់យាម មកគូសខ្វែងចុះឡើង ហើយរាប់តាមលេខថា:

ប៉កស៊ិកប៉កស៊ី ដើរក្តាមប្រាំបី
បេកផុតដំឡូងស្ងោរ . . . .
អត្តខ្លួនប្រាណ ប្រាក់បាត់ពុំបាន
នៅក្នុងទីនេះ . . . . .
អត្តខ្លួនហើយទឹងប្រាណ
ទៅណាពុំបាន នៅលើអាប្រាណ ។

រួចហើយតាសួសសួរព្រះពជា ថា ៖

បពិត្រមហាពជ អាមាត្យព្រះអង្គមានឈ្មោះអាប្រាណដែរឬទេ ?

— ករុណា ម្ចាស់មាន

— បើដូច្នោះ ព្រះមហាពជគ្មានទៅណាទេ មុខជាឈ្មោះអាប្រាណវាលួចយកទៅ ព្រះពជាឮហើយ បានឲ្យពេជ្ឈឃាតចាប់យកខ្លួនអាប្រាណមកសួររកប្រាក់ទាល់តែឃើញមែន ទើបឲ្យពេជ្ឈឃាតនាំយកអាប្រាណទៅសម្លាប់ចោលទៅ ។ ទ្រង់ពោលសរសើរលោកតាសួស



ថាចេះទាយត្រូវតែមែន ទើបព្រះពជាទ្រង់ប្រទានប្រាក់មួយការុង ទៅលោកតាសួស ។

ព្រះរាជាសួរទៀតថា ៖

ចុះលេខទាយព្រះគុណម្ចាស់រាប់ថាប៉ក់អិតប៉ក់អីដូច្នេះមែនឬ ?

– ថ្វាយព្រះពរលេខអាត្មាភាពយ៉ាងហ្នឹងមែន

– បើយ៉ាងហ្នឹងមែន ព្រះករុណាសូមថ្វាយព្រះនាមដល់ព្រះគុណម្ចាស់ ប៉ក់អិតប៉ក់អីទៅវិញ ដើម្បីឲ្យងាយបំណាំចាំបានទៅថ្ងៃមុខថ្ងៃក្រោយទៀត , មែនពិតកាលពីដើមឈ្មោះ លោកគ្រូប៉ក់អិតប៉ក់អីទេ លុះយូរមកទើបក្លាយមកគេហៅថា លោកគ្រូអិតអីជាប់មកដល់សព្វថ្ងៃនេះ ។ រួចហើយលោកគ្រូអិតអីក៏ចំរើនពរព្រះរាជាវិលត្រឡប់មកកាន់ទីលំនៅវិញ ; លុះនៅយូរមកលោកគ្រូអិតអីរកស៊ីចិញ្ចឹមជីវិតបែបនេះជារៀងរាល់ឆ្នាំ ដរាបដល់ខ្លួនលោកចាស់ទ្រុឌទ្រោមគ្រាំគ្រាបន្តិចមក ក៏គិតឧបាយមួយផ្សេងពីនោះ ថាអាត្មាអញបើរកស៊ីចិញ្ចឹមជីវិតបែបនេះ មុខជាមហន្តរាយណាមួយមកនាំខ្លួនអាត្មាអញទៅឲ្យសោយសេចក្តីទុក្ខលំបាកមិនខាន ណ្ហើយបើដូច្នេះអាត្មាអញតាំងចិត្តផ្តាច់បង់នូវអំពើជាអកុសលទាំងនេះចេញ កិរិយាបែបនេះមុខជាពុំបានសុខទេ ធម្មតាអ្នកដើរក្លួតករកុហកគេ មិនដែលបានសុខបានចំរើនទេ ពិតប្រាកដជាប៉ះពាទៅលើទុក្ខណាមួយ មានប៉ះបំទៅលើសេចក្តីទុក្ខលំបាក ស៊ើរតែស្លាប់ក៏សឹងមានដែរ សមដូចពាក្យបុរាណលោកពោលថា ៖

លួចគេរាំគ្រាន់ តែគេទាន់មុខជាក្រែល ...

ពេលខាងក្រោយមក លោកគ្រូអ៊ិកអ៊ី បានឮពួកក្មេងអ្នកស្រុករាំបបួលគ្នា ច្រៀងលេងថា ៖

ពុំកួងដួងមីលាន់ លួចគេរាំគ្រាន់
តែគេទាន់រាំក្រែល .....
ពុំកួងដួងមីលាន់ កូតគេរាំគ្រាន់
គេដេញទាន់រាំក្រែល .....
ពុំកួងដួងមីលាប់ បើកូតពុំគាប់
វិនាសខ្លួនប្រាណ ..... ៗ

លោកគ្រូអ៊ិកអ៊ី ឮពាក្យនោះហើយ មានចិត្តត្រេកអរបន្តិច ទោមនស្សបន្តិច គិតទៅថ្ងៃមុខថ្ងៃក្រោយ រួចហើយបែរទៅជាយំសោក យំសោករួចហើយបែទៅជាសើចសប្បាយតែម្នាក់ឯងទៅវិញ ពេលដែលសើចសប្បាយ ព្រោះនឹកឃើញថា បើអញកូតគេនោះជួនជាគាប់ ពេលដែលយំសោកព្រោះនឹកឃើញថា បើអញកូតគេទៅជួនជាពុំគាប់ មុខជាជាប់ទោសតាំងក្នុងលោកនេះ និងលោកខាងមុខ ទោសធ្ងន់ណាស់ ! ហើយខ្លួនអញជាសង្ឃផងពុំគួរសោះ !!

លោកគ្រូអ៊ិកអ៊ី គិតឃើញដូច្នោះ ក៏លះបង់អំពើកូតករចេញតាំងពីពេល

នោះមកព្រមទាំងកូនសិស្ស ៣ នាក់ ក៏បែកផ្លូវគ្នា ចិញ្ចឹមជីវិតតាមសម្មា-ជីវភាពរៀងៗខ្លួន រហូតមក ៗ រៀងរ៉ៃនេះ អស់សេចក្ដីតែប៉ុណ្ណេះ

៦៥ ៗ

កវី សុខ - ប៊ឿ

រៀបរៀង

សៀវភៅប្រលោមលោកតែងដោយ

# អ្នកស្រី ស៊ុយ.ហៀង

## មានបោះពុម្ពផ្សាយហើយ

១ - ភាសានៃនាងណាត្រី — តម្លៃ ១ ក្បាល ១២រ

២ - ស្នឹងក្រហម ទី ១ នឹងទី ២ ចប់ — តម្លៃ " ១២រ

៣ - ផ្ការីកផ្ការោយ — តម្លៃ " ១២រ

៤ - កូនក្រកមេបោរ ទី ១ នឹងទី ២ ចប់ — តម្លៃ " ១៤រ

## បំរុងបេញនៅថ្ងៃក្រោយ

១ - អ្នកណាសម្លាប់នាយមែន ?

២ - ភាលខ្លាច់ស

៣ - ពន្លឺប្រទីបក្នុងរូងភ្នំ

៤ - ភ្លើងឆេះនៅចំការចិន

៥ - ថ្មកណរាមផក់កប់ក្នុងស្រែ

៦ - ស្នេហាគ្មានពិបារណា

# ខេមរបណ្ណាគារ និងរោងពុម្ព

ផ្ទះលេខ ៣ វិថីកាំទរ៉ូឡង់ហ្វូវ៉ង់ ខាងកើតផ្សារធំថ្មី ភ្នំពេញ សូមថ្វាយប្រគេន ជូនដំណឹង សូមទ្រង់ជ្រាប បានជ្រាប ជ្រាប ៗ

ខេមរបណ្ណាគារ ជាបណ្ណាគាររបស់ខ្មែរតែមួយ ដែលធំជាងគេក្នុងកម្ពុជរាជធានី មានសៀវភៅខ្មែរ-បារាំង-អង់គ្លេស ព្រមទាំងប្រដាប់ប្រដាឯទៀត ៗ ជាច្រើន សំរាប់គ្រូនិងសិស្សរៀនសូត្រ ឬមើលកំសាន្ត ៗ

សព្វថ្ងៃកំពុងតែបោះពុម្ពផ្សាយ មានរូបភាពផ្សេង ៗ និងសៀវភៅច្រើនមុខ ក្នុងមួយខែមានចេញ ៤ រឿងរៀងរាល់ខែ មានលក់ដុំនិងលក់រាយ ផ្ញើជូនគ្រប់ខេត្តគ្រប់ស្រុក ព្រមទាំងទទួលជួលបោះពុម្ពអក្សរសាស្ត្រ តាមបំណងលោក-អ្នក គិតថ្លៃថោកគួរសមជូន ៗ

សៀវភៅបោះពុម្ពរួចហើយគឺ.

១- សុភាសិតបារាំង ប្រែជាពាក្យកាព្យខ្មែរ លោកប៉ាយ-ប៊ុក រៀបរៀង ភាគ ១ និងភាគ ២-១ ក្បាល ៦៛.០០

២- រឿងប្រលោមលោក វិស្ណាខែនាងណាគ្រី អ្នកស្រីស៊ុយ ហឿង រៀបរៀង ១០៛០០

៣- បបញ្ចធម៌ ព្រះមហាទ-អ៊ុម-ស៊ុម រៀបរៀង ៦៛០០

៤- ចម្រៀង " ឡាំប៊ូគ " និងចម្រៀងសម័យ បោះពុម្ពលើកថ្មី ៨៛០០

៥ _ ប្រវត្តិនៃ "មហាត្មគន្ធី" លោក វ៉ាយ-ប៊ុក រៀបរៀង

១៥រ០០

៦ _ "ពុទ្ធវិបស្សនាយកឋា" សម្តែងអំពីប្រជុំនៃពុទ្ធវចនៈវិទ្យុ

ធម្មទេសនាគិតុមហាទ. ឈឹម-ម៉ឺ ធម្មប្បវត្តិ រៀបរៀង ៥រ០០

៧ _ រឿងព្រេងបូរាណផ្សេងៗ ភាគមួយមានរឿងមរណៈមាតា

រឿងវន្ទះ, រឿងមនុស្សដើកគ្ណាម ៩រ០០ មានភាគ ២ ហើយមានចេញ

ភាគត ៗ ទៅទៀតជាលំដាប់

៨ _ រឿងនាងបទុមវតី ៦រ០០

៩ _ រឿងប្រលោមលោក "ស្នឹងក្រហម" ជារឿងកំសត់

អ្នកស្រី ស៊ុយ-ហៀង រៀបរៀង ១២រ០០

១០ _ រឿងព្រេង "សុបិន" ជារឿងព្រេងពាក្យកាព្យ ៦រ០០

១១ _ "ធនញ្ជ័យ" ពាក្យកាព្យទី ១ ៦រ០០

១២ _ កែវគុណ រឿងព្រេងចិន ទី ១-២ ១០រ០០

១៣ _ មាយើង ស្រែកញ្ចើញុះទឹងស្រីគ្រប់លក្ខណ៍ ៧រ០០

១៤ _ ផ្ការីកផ្ការោយ អ្នកស្រី ស៊ុយ ហៀង តែង ១២រ០០

១៥ _ ពុទ្ធទំនាយ ៥រ០០

១៦ - បិនលីគម្ពីរស្វែងរកព្រះបាទធម្មិករាជ ៩,០០

១៧ - ព្រះរាជពង្សាវតារនគរខ្មែរ ១០,០០

១៨- តំណាក់ឈាមលើផ្កាកុលាប ១១,០០

*លោក ប៊ុំ-ឆៃ លាង តែង*

១៩- រឿងមកុដពេជ្រ *លោក* ប៊ុំ-ឆៃ-លាង ទី១ ១០,០០

ទី២ ១២,០០

២០- បុណ្យអភិធម្ម និង ប្រស្នាអភិធម្ម ១០,០០

២១- រឿងអាឡេវ ៧,០០

២២- រឿងចៅខ្វាក់ចៅខ្វិន ៨,០០

២៣- រឿងលោកគ្រូអ៊ិកអ៊ី

២៤- មេសូត្រសំរាំង (សំរាប់គ្រូនឹងសិស្ស)

២៥- ហាត់អានសម័យនិយម

២៦- និ-សាន ទុគិត *ស្រី-ឡុប រៀបរៀង*

២៧- Recueil dedictées C.E.P. 12$

២៨- Recueil de problèmes C.E.P 12$

២៩- Recueil de rédactions C.E.P 12$

៣០ - Géographie de l Indochine à paraitre

ពុទ្ធសាសនបណ្ឌិត្យ